ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Feb-2015, 14:55
CMS/CFO: Sann Rada

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥**

**ម៉ោង ០៩:០៩នាទី**

**សវនាការលើកទី២៤៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin Karopkin)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ជា ស៊ីវហ័ង

លោក ហ្វីលីព រ៉ូជឺ *(Mr. Roger Phillips)*

លោក រ៉ូស៊ែល ហាប់គីនស៍
*(Mr. Russell HOPKINS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ឌេល លីសាក់ *(Mr.Dale LYSAK)*

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de Wilde d'Estmael)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គិសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ឡេ ផុនធី

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោក ហុង គីមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ស្រី ថន ហៅ ឌុច (2-TCW-944) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ស្រី ថន ហៅ ខុច** (2-TCW-944)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................................ទំព័រ ៣

សួរដោយលោក ឌេល លីសាក់ ផ្ដើមពី.................................................................... ទំព័រ ៧

# កិច្ចដំណើរការនីតិវិធី

[០៩:០៩:១៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមគម្រោងថ្ងៃនេះ អង្គជំនុំជម្រះបានកំណត់កាលវិភាគសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-944 រហូតដល់បញ្ចប់ការសួរដេញដោលដោយសហព្រះរាជអាជ្ញា។

ក្រឡាបញ្ជីសវនាការលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍ពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួន ខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សី ដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-944។ សាក្សីរូបនេះ និង មេធាវីប្រឹក្សារបស់សាក្សី លោក ឌុច ផារី មានវត្តមាននៅបន្ទប់រង់ចាំៗការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបឋមនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថាដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃមុខឲ្យមានប្រសិទ្ធភាព ខ្លួនលះបង់សិទ្ធិចូលរួមនិងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥។ ហើយគាត់ មេធាវីការពារក្តីរបស់គាត់ របស់ខ្លួនបានជម្រាបអំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាច

បកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:១២:០២]

បានឃើញកំណត់ហេតុពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ បានកត់សម្គាល់ឃើញថា ស្ថានភាពសុខភាពរបស់លោក នួន ជា មិនមានការប្រែប្រួលទេ គឺមានអាការៈឈឺចង្កេះខ្លាំង វិលមុខពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនេះនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា បានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

កាលពីម្សិលមិញអង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីថាអង្គជំនុំជម្រះបានទទួលនូវសំណើសុំវិធានការការពារចំពោះសាក្សី ហើយបានសម្រេចផ្អាកសវនាការរហូតមកដល់ថ្ងៃនេះ។ អង្គជំនុំជម្រះរំឭកឡើងវិញថាវិធាន៧៩(៦) នៃវិធានផ្ទៃក្នុងដែលចែងថាសវនាការត្រូវធ្វើឡើងជាសាធារណៈ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះអាចសម្រេចធ្វើសវនាការជាអសាធារណៈបានដើម្បីប្រសិទ្ធភាពនៃវិធានការការពារដើម្បីពិភាក្សាលើសំណើសុំវិធានការការពារខាង -- ដូចខាងលើនេះ អង្គជំនុំជម្រះសម្រេចធ្វើសវនាការជាអសាធារណៈ អនុលោមតាមវិធាន ២៩ នៃវិធានផ្ទៃក្នុង។

បាទ អង្គជំនុំជម្រះបង្គាប់ឲ្យផ្នែកសន្តិសុខអញ្ជើញសាធារណជនដែលស្ថិតនៅខាងក្រៅកន្លែងសម្រាប់សាធារណជនហ្នឹង ចេញក្រៅសាលសវនាការសិន មួយរយៈសិនណ៎ា នៅក្នុងអំឡុងពេលដែលអង្គជំនុំជម្រះធ្វើសវនាការជាអសាធារណៈ។ ហើយអង្គជំនុំជម្រះសូមជូនដំណឹងដល់មន្ត្រីរដ្ឋបាល

តុលាការ ពីការប្រព្រឹត្តិនៃសវនាការសាធារណៈវិញនៅពេលអង្គជំនុំជម្រះសម្រេចដូច្នេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ផ្ដាច់សំឡេង និងរូបភាពចេញទៅក្រៅសវនាការ ប៉ុន្តែវាំងននដដែលនៅបើកដដែលដើម្បីសម្រួលដល់អ្នកបកប្រែភាសា។

*(សវនាការអសាធារណៈចាប់ពីម៉ោង ០៩:១៧នាទី ដល់ម៉ោង ១០:០០នាទី)*

*(សវនាការសាធារណៈបន្តពីម៉ោង ១០:៣០ នាទី)*

[១០:៣០:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ ហើយមុននឹងដំណើរស្ដាប់សក្ខីកម្មសាក្សី អង្គជំនុំជម្រះលើផ្ទាល់មាត់ ចេញសេចក្ដីសម្រេចលើផ្ទាល់មាត់លើសំណើសុំវិធានការការពាររបស់សាក្សីដែលមានរហស្សនាម 2-TCW-944។

អង្គជំនុំជម្រះយល់ព្រមលើសំណើសុំវិធានការពារដែលស្នើឡើងដោយសាក្សី 2-TCW-944 ដែលធ្វើឡើងតាមរយៈអង្គភាពគាំពារសាក្សី និង អ្នកជំនាញ។ ព័ត៌មានលម្អិតស្ដីពីអាសយដ្ឋានសាក្សីមិនត្រូវផ្សព្វផ្សាយដល់សាធារណជនឡើយ។ មិនអនុញ្ញាតឲ្យចេញរូបភាពសាក្សីរូបនេះ ទៅសាធារណជន។ ដើម្បីអនុវត្តវិធានការការពារនេះ រូបភាពរបស់សាក្សីនឹងត្រូវបំលែងដោយបច្ចេកវិទ្យាក្នុងពេលដំណើរការសវនាការស្ដាប់សក្ខីកម្មរូបនេះ។ សេចក្ដីសម្រេចមានសំអាងហេតុពេញលេញ អង្គជំនុំជម្រះនឹងចេញនាពេលឆាប់ៗខាងមុខនេះ។

បាទ តទៅនេះ អង្គជំនុំជម្រះបង្គាប់ឲ្យខាងផ្នែកសោតទស្សន៍បំលែងរូបភាពមុខសាក្សីនៅក្នុងអំឡុងពេលដំណើរការសវនាការ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សាក្សី តើលោកឈ្មោះអី?

**លោក ស្រី ថន៖**

**ឆ៖** ខ្ញុំឈ្មោះ ស្រី ថន។

**ស៖** ឆ្នាំកំណើតរបស់លោក លោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆ៖** កើតនៅឆ្នាំ១៩៥៧។

**ស៖** អរគុណ។ ហើយតើមុខរបររបស់លោកធ្វើអ្វី?

**ឆ៖** មុខរបរសព្វថ្ងៃ ធ្វើស្រែ។

**ស៖** ហើយឪពុករបស់លោក ឈ្មោះអី? ម្ដាយរបស់លោក ឈ្មោះអី?

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ ទុយ ងិល។ ម្ដាយឈ្មោះ ទុយ ជឹម។

[១០:៣៤:០០]

**ស៖** ហើយប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ ឡុង វុន មានកូនក្នុងបន្ទុកប្រាំនាក់។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីសវនាការយកឯកសារ D125/129 នេះ យកទៅជូនសាក្សីពិនិត្យលើចំណុច *ហាយឡាយ* នេះ ហើយឲ្យគាត់បញ្ជាក់ ថាតើចំណុចនេះ ត្រឹមត្រូវដែរឬទេ?

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើត្រឹមត្រូវដែរឬទេ អាសយដ្ឋាននោះ?

**ឆ៖** បាទ ពិតជាត្រឹមត្រូវ។

**ស៖** បាទ អរគុណសាក្សី។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ ថាតាមសមត្ថភាពដែលលោកអាចដឹង លោកមិនមានឪពុកម្ដាយ បុព្វញាតិ កូន បច្ឆាញាតិ បងប្អូនប្រុសស្រី បងប្អូនថ្លៃ ប្រពន្ធត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពិតប្រាកដមែន។

**ស៖** តើលោកសាក្សីបានស្បថហើយឬនៅ?

**ឆ៖** បាទ បានស្បថរួចហើយ។

**ស៖** ឥឡូវនេះ យើងប្រាប់អំពីសិទ្ធិនិងករណីយកិច្ចរបស់លោកក្នុងលោកចូលរួមជា ធ្វើជាសាក្សីនៅចំពោះអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោកក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការសុំឲ្យលោកធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួន

ឯង។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះហើយ ដែលនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

[១០:៣៦:៣៥]

ករណីយកិច្ចក្នុងនាមលោកជាសាក្សី នៅក្នុងការផ្ដល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយ ដែលភាគី ឬអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរដែលនាំឲ្យឆ្លើយតបរបស់លោក ឬក៏ការអត្ថាធិប្បាយរបស់លោកមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរបស់លោករួចហើយអម្បាញ់មិញនេះ។ ក្នុងនាមលោកជាសាក្សីត្រូវឆ្លើយឲ្យការដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរលោក។ តើលោកយល់ទេអំពីសិទ្ធិ និងករណីយកិច្ចនេះ?

**ឆ៖** បាទ ខ្ញុំបាទយល់។

**ស៖** អរគុណ។ ហើយតើលោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ? ហើយប្រសិនបើមានធ្លាប់ធ្វើប៉ុន្មានដង? ហើយធ្វើនៅទីកន្លែងណាខ្លះ?

**ឆ៖** បាទ ខ្ញុំបានធ្វើសក្ខីកម្មប្រហែលជាពីរបីដងហើយ ប៉ុន្តែខ្ញុំមិនចាំៗថ្ងៃ មិនចាំពេលវេលាចំនួនពីរបីដងហើយ។

**ស៖** លោកចាំថា កាលធ្វើហ្នឹងធ្វើនៅទីកន្លែងណាទេ?

**ឆ៖** ធ្វើនៅក្នុងផ្ទះរបស់ខ្ញុំបាទផ្ទាល់។

**ស៖** បាទ អរគុណ។ ហើយមុននឹងចូលមកមុខអង្គជំនុំជម្រះនាពេលនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានផ្ដល់សក្ខីកម្មកាលពីលោកធ្វើនាពេលមុនៗនៅផ្ទះរបស់លោកកន្លងមកនេះ ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានពិនិត្យមើលរួចរាល់អស់ហើយ។

**ស៖** តាមសមត្ថភាពដែលលោកអាចដឹង និងលោកចងចាំ តើលោកអាចបញ្ជាក់បានដែរទេថាកំណត់ហេតុដែលស្ដាប់ចម្លើយរបស់លោក ដែលលោកបានអានដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹម

ត្រូវ ឬវាសមស្របស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសជាមួយនឹងអ្នកស៊ើបអង្កេតកាលពីមុនដែលលោកអះអាងថាធ្វើនៅផ្ទះរបស់លោកនោះដែរឬទេ?

[១០:៣៩:១២]

**ឆ៖** ពិតប្រាកដមែន។

**ស៖** ហើយនៅក្នុងអំឡុងពេលនេះ តើលោកបាន -- ឥឡូវនេះ លោកបានទទួលមេធាវីប្រឹក្សាហើយ ដោយមានការចាត់តាំងពីអង្គជំនុំជម្រះតាមរយៈអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ តាមសំណើសុំរបស់លោក។ មុននេះតើលោកបានប្រឹក្សាពិភាក្សាយោបល់ជាមួយនឹងមេធាវីរបស់លោកហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបានប្រឹក្សាយោបល់ជាមួយនឹងមេធាវីរបស់ខ្ញុំបាទរួចហើយ។

**ស៖** ឥឡូវនេះជាការល្អណាស់ ដោយសារលោកមានបានប្រឹក្សារួចហើយ ប៉ុន្តែមិនមែនមានន័យថាអង្គជំនុំជម្រះមិនអនុញ្ញាតឱ្យលោកប្រឹក្សាជាមួយនឹងមេធាវីរបស់លោកតទៅទៀតនោះទេនៅក្នុងការស្ដាប់សំណួរទាំងលោក ទាំងមេធាវីប្រឹក្សារបស់លោកគឺស្ដាប់សំណួរដែលសួរ។ ប្រសិនបើសំណួរណា ឬក៏ការដែលសុំឱ្យលោកធ្វើអត្ថាធិប្បាយ ឬអះអាងណាមួយ ដែលទំនងជាចម្លើយតបរបស់លោកនុ៎ះ គឺមានលទ្ធភាពក្នុងការពិរុទ្ធភាពលើខ្លួនឯង ដាក់ពិរុទ្ធភាពលើខ្លួនឯងនោះ លោកអាចប្រឹក្សាយោបល់ជាមួយនឹងមេធាវីរបស់លោក ដើម្បីថាតើឆ្លើយឬក៏មិនឆ្លើយ។ សិទ្ធិឆ្លើយជាសិទ្ធិរបស់លោក ឆ្លើយឬក៏មិនឆ្លើយនោះ គឺជាសិទ្ធិរបស់លោក ប៉ុន្តែសូមឱ្យច្បាស់ថា ទាល់តែសំណួរណាដែលវាមានស្ថានភាពថាលទ្ធផលនៃការឆ្លើយតបនុ៎ះ គឺជា -- និងផលវិបាកហ្នឹងវាធ្លាក់មកលើលោក ដោយសារវាអាចដាក់ពិរុទ្ធភាពលើខ្លួនឯង។

ហើយទី២ មួយទៀតដើម្បីបញ្ជាក់ឱ្យច្បាស់លាស់ថ្ងៃនេះ បានន័យថារាល់សំណួរត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរដោយភាគី ឬចៅក្រមអង្គជំនុំជម្រះ។ ចម្លើយតបហ្នឹងមិនមែនសុទ្ធតែមានលទ្ធផលវិជ្ជមានទាំងអស់ទេ ក្នុងករណីដែលមិនដឹង គឺលោកអាចឆ្លើយថាមិនដឹងអំពីហេតុការណ៍ មិនដឹងមិនឮមិនដែលបានទទួលបានព័ត៌មានអី គឺឆ្លើយមិនដឹង ក៏ជាចម្លើយដែរ។ ច្បាស់លាស់ទេ?

[១០:៤១:១៤]

**ឆ៖** បាទ ខ្ញុំស្ដាប់បាន ស្ដាប់បានច្បាស់លាស់ហើយ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមវិធាន ៩១ស្ទួន នៃវិធានផ្ទៃក្នុង

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនរឿងក្តី។ សូមអញ្ជើញសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** អរុណសួស្តីលោកសាក្សី ខ្ញុំសូមចាប់ផ្តើមសួរសំណួរ ទាក់ទងទៅនឹងអំឡុងពេលចន្លោះពីឆ្នាំ១៩៧៣ ទៅដល់៧៦ នៅពេលដែលលោកធ្វើជាទាហាននៅស្រុក -- កងទ័ពនៅស្រុកត្រាំកក់។ កំណត់ហេតុស្តាប់ចម្លើយជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត D125/129 លោកបញ្ជាក់ថាលោកបានក្លាយទៅជាកងទ័ពខ្មែរក្រហម នៅក្នុងចុងឆ្នាំ១៩៧៣ ហើយលោកបានប្រយុទ្ធជាមួយនៅជាមួយនឹងទាហានលន់ នល់ នៅក្នុង -- នៅវរសេនាធំលេខ១៣ គឺវាប្រយុទ្ធនៅពេលដែលខ្មែរក្រហមក្តោបក្តាប់បានអង្គតាសោម។

[១០:៤៣:០៧]

**លោក ស្រី ថន៖**

**ឆ៖** ខ្ញុំៗបាទ នៅឆ្នាំ១៩៧៣ ខ្ញុំបាទធ្វើជាកងទ័ពស្រុក។ ចុងឆ្នាំ១៩៧៣ ខ្ញុំចូលទៅកងទ័ព ហៅថាកងទ័ពតំបន់ សម័យខ្មែរក្រហម គេហៅថា "ទ័ពតំបន់"។ ទ័ពតំបន់ហ្នឹងនៅក្នុងកងវរៈ២១ ហើយកងពលខ្ញុំអត់ដឹងទេ អត់ៗចាំ ដូចគ្នានកងពល មានតែត្រឹមវរសេនាធំ ហ្នឹងក្នុងអំឡុងឆ្នាំ១៩៧៣។ ដល់ឆ្នាំ១៩៧៥ ពេលខ្មែរក្រហមបែកភ្នំពេញ ខ្ញុំឡើងទៅនៅកងពល២១០ វរសេនាធំ១៣ កងពលលេខ៣។

**ស៖** សូមអរគុណ។ មុនយើងចូលទៅដល់ខែមេសា ១៩៧៥ តើលោកមានចាំអ្វីពាក់ព័ន្ធទៅនឹងការរឹបអូសបានអង្គតាសោមដែរឬទេ?

**ឆ៖** កាលនោះ ខ្ញុំមិនចាំ។

**ស៖** ឥឡូវនេះ នៅក្នុងចម្លើយលើកទី១ របស់លោកក្នុងឯកសារ D125/124, ERN ជាភាសាខ្មែរ 00224788, អង់គ្លេស 00231673 ទៅដល់ 74, ERN ជាភាសាបារាំង 00234574 ដល់ 75។ លោកបានឆ្លើយថាលោកស្ថិតនៅក្រុងតាកែវនៅថ្ងៃ១៧ មេសា ១៩៧៥ ដើម្បីរៀបចំការប្រយុទ្ធ ហើយក្រុងតាកែវហ្នឹងក៏បានដួលរលំនៅថ្ងៃ១៨ មេសា ១៩៧៥ ហើយលោកបានរៀបរាប់នូវអ្វីលោកបានឃើញ

ដូចតទៅនេះ ខ្ញុំសុំដកស្រង់៖ "ខ្ញុំបានឃើញទាហានលន់នល់ លើកទង់សសុំចុះចាញ់ ហើយខ្ញុំបានឃើញកងទ័ពខ្មែរក្រហមប្រដាប់ទៅដោយអាវុធបង្ខំប្រជាជនឲ្យចាកចេញពីទីក្រុងតាកែវទៅទិសខាងលិចតាមផ្លូវជាតិលេខ២២ រហូតដល់រសៀលម៉ោងប្រាំទើបមានសភាពស្ងប់ស្ងាត់"។ បញ្ចប់ការដកស្រង់។

សំណួររបស់ខ្ញុំគឺ តើទាហាន លន់ នល់ ដែលសុំចុះចាញ់នៅក្រុងតាកែវហ្នឹង គេធ្វើយ៉ាងម៉េចដែរ? គេចាត់ចែងយ៉ាងម៉េចដែរ?

**ឆ៖** ពេលដែលទាហាន លន់ នល់ ចេញពីទីក្រុងតាកែវ គឺគេបញ្ជូនមកឲ្យនៅសហករណ៍ក្នុងស្រុកត្រាំកក់ហ្នឹង។

**ស៖** តើមានទាហាន លន់ នល់ ឬក៏អ្នករដ្ឋការ ជាពិសេសអ្នកដែលមានបុណ្យស័ក្តិខ្ពង់ខ្ពស់ត្រូវបានចាប់ខ្លួនដែរឬទេ នៅក្នុងពេលគេបង្ខំឲ្យចេញពីក្រុងតាកែវនោះ?

**ឆ៖** បាទ នៅពេលនោះ ខ្ញុំមិនបានដឹងទេ។

**ស៖** លោកមានស្គាល់ទីតាំងមួយ គេហៅថាមន្ទីរ២០៤ ដែលមានទីតាំងនៅព្រៃក្តួចនៅទិសបស្ចិមនៃអង្គតាសោម នៃស្រុកត្រាំកក់ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់។

**លោក ឌេល លីសាក់៖**

ឥឡូវនេះ ខ្ញុំសុំដកឃ្លាបន្តិច ហើយសុំបង្ហាញឯកសារ E319.1.5។ ខ្ញុំសុំការអនុញ្ញាតសូមផ្តល់ឯកសារនេះជូនទៅដែលជាចម្លើយពីការិយាល័យសហចៅក្រមស៊ើបអង្កេត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

[១០:៤៩:៣២]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ចម្លើយរបស់លោកដែលខ្ញុំយោងនោះគឺ ចម្លើយលេខ៣ គឺឯកសារ E319.1.25។ លោកបានឆ្លើយថា៖"បន្ទាប់ពីចាកចេញពីក្រាំងតាចាន់ ខ្ញុំត្រូវគេបញ្ជូនទៅព្រៃក្តួច និងទៅទីកន្លែងជាច្រើនទៀតគឺ-- ប៉ុន្តែកន្លែងទាំងអស់នេះ គឺស្ថិតនៅក្នុងភូមិភាគនិរតី"។ បញ្ចប់ការដកស្រង់។ នៅពេលដែលគេបញ្ជូនលោកទៅព្រៃក្តួច តើគេចាត់ឲ្យលោកទៅធ្វើការនៅមន្ទីរ២០៤ ឬក៏អត់? ហើយនៅព្រៃក្តួចគេចាត់តាំងឲ្យលោកធ្វើអ្វីដែរ?

**ឆ៖** បាទ ពេលដែលគេបញ្ចេញខ្ញុំពីក្រាំងតាចាន់ទៅវិញនេះ គឺខ្ញុំទៅចូលនៅកងពលរបស់ខ្ញុំវិញ ខ្ញុំបាទវិញ។ ប៉ុន្តែមិនមែនទៅនៅព្រៃក្ដួចទេ ទៅនៅកងពល២១០ វីរសេនាធំ១៣វិញ។

**ស៖** អ៊ីចឹង តើមានពេលណាមួយលោកធ្លាប់ធ្វើការនៅព្រៃក្ដួច ឬក៏ហៅថាមន្ទីរ២០៤ ដែរទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** ខ្ញុំសូមសួរសំណួរទាក់ទងទៅនឹងព្រឹត្តការណ៍ភ្លាមៗបន្ទាប់ពីថ្ងៃ១៧ មេសា ១៩៧៥។ យើងបានស្ដាប់សក្ខីកម្មពីសាក្សីម្នាក់ឈ្មោះ កែវ ចិន្ដា -- កែវ ចាន់តារ៉ា ហើយនៅក្នុងចម្លើយរបស់គាត់ គឺ E3/5153 ជាមួយសហចៅក្រមស៊ើបអង្កេត នៅ ERN ជាអង់គ្លេស 00205090, ERN ភាសាខ្មែរ 00172044, ERN ភាសាបារាំង 00205095។ សាក្សីរូបនេះបានរៀបរាប់អំពីថាតើអ្នកត្រូវភៀសខ្លួនអ្នកដែលត្រូវគេបញ្ជូនៗទៅវត្តចំប៉ា ស្រុកត្រាំកក់ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ហើយគាត់បាននិយាយថា៖ "អ្នកដែលគេជម្លៀស ៧០ភាគរយទៅស្នាក់នៅៗឯវត្តចំប៉ា គឺត្រូវគេសម្លាប់នៅក្រាំងតាចាន់ ក្របីព្រៃ មន្ទីរ១៦០ និង មន្ទីរ២០៤"។ បញ្ចប់ការដកស្រង់។ សូមលោកជួយប្រាប់បន្តិចមើលថាតើ អ្នកដែលជម្លៀស គេជម្លៀសទៅស្រុកត្រាំកក់ហ្នឹងត្រូវគេប្រមូលផ្ដុំដាក់នៅវត្តចំប៉ា ឬក៏អត់ក្រោយថ្ងៃ១៧ មេសា ១៩៧៥? ហើយតើមានអ្វីកើតឡើងទៅដល់អ្នកជម្លៀសទាំងនោះ?

**ឆ៖** បាទ ពេលៗខ្មែរក្រហមវាយភ្នំពេញដួលរលំ ថ្ងៃ១៧ មេសាហ្នឹង ខ្ញុំបានអត់បាននៅស្រុកត្រាំកក់ទេ ហើយមិនដឹងសភាពការណ៍ហ្នឹងយ៉ាងម៉េចដែរ ខ្ញុំមិនដឹង។

[១០:៥៣:៤៥]

**ស៖** ពេលណាលោកត្រឡប់មកធ្វើការនៅស្រុកត្រាំកក់ក្រោយថ្ងៃ១៧ មេសា ៧៥។ ពេលណាលោកត្រឡប់មកធ្វើការនៅស្រុកត្រាំកក់?

**ឆ៖** បាទ ខ្ញុំមិនបានធ្វើការនៅក្នុងស្រុកត្រាំកក់ទេ ព្រោះខ្ញុំជាទាហាន ធ្វើការនៅកងពល២១០ វរសេនាធំ១៣។

**ស៖** តើវរសេនាធំលេខ១៣ ហ្នឹងមានទីតាំងនៅឯណាដែរ នៅពេលដែលលោកធ្វើជាទាហានហ្នឹង?

**ឆ៖** ពេលដែលទីតាំងពិតប្រាកដ គឺអត់មានទេ គឺចល័តរហូត។

**ស៖** តើលោកអាចឆ្លើយ ឬក៏រៀបរាប់អំពីទិដ្ឋភាពទូទៅ ទីតាំងដែលលោកស្ថិតនៅក្នុងអំឡុងពេលបន្ទាប់ពី ១៧ មេសា ២៩៧៥ នៅរហូតពី៧៥ ទៅដល់ ៧៦។ សូមលោករៀបរាប់លម្អិតបន្តិច?

[១០:៥៥:00]

**ឆ៖** បាទ បើចាប់ពីឆ្នាំ១៩៧៥ មកពេលនោះរំលងបានប្រហែលជាមួយខែ ខ្ញុំនៅភ្នំនរាយ រ៉ៃថ្ម។ ក្រោយមកបានចុះទៅស្រុកកោះអណ្ដែតគីរីវង់ ទៅធ្វើស្រែ។ ហើយនៅគ្រប់កន្លែងដើរធ្វើស្រែ ប៉ុនមិនចាំទីកន្លែងពិតប្រាកដ។

**ស៖** ឥឡូវនេះ ខ្ញុំសូមត្រឡប់ចូលទៅអំឡុងពេលដែលលោកធ្វើការនៅក្រាំងតាចាន់។ ខ្ញុំសូមសួរបន្តពីសំណួរចុងក្រោយ។ តើមានអំឡុងពេលណា មុនពេលគេចាត់ឲ្យលោកទៅធ្វើការនៅក្រាំងតាចាន់? តើលោកធ្លាប់ដែលធ្វើការនៅស្រុកត្រាំកក់ មុនទៅក្រាំងតាចាន់ដែរឬទេ? ឬក៏ថា ខ្ញុំសួរថាពេលណាដែលគេបញ្ជូនលោកទៅធ្វើការនៅស្រុកត្រាំកក់ជាលើកទី១ មុននឹងបញ្ជូនលោកទៅក្រាំងតាចាន់?

**ឆ៖** បាទ អត់មានទេ។

**ស៖** ខ្ញុំចង់និយាយអំពីអំឡុងពេលដែលលោកធ្វើការនៅក្រាំងតាចាន់។ នៅក្នុងចម្លើយលេខ៣ជាមួយសហចៅក្រមស៊ើបអង្កេតគឺ E319.1.25។ សំណួរសួរថា “ពេលណាលោកចាប់ផ្ដើមធ្វើការនៅក្រាំងតាចាន់?” ហើយចម្លើយរបស់លោក សូមដកស្រង់៖ “ក្នុងឆ្នាំ១៩៧៦ ឬ១៩៧៧” ហើយនៅក្នុងចម្លើយផ្សេងមួយទៀត លោកឆ្លើយថាឆ្នាំ១៩៧៧ គឺជាពេលដែលគេចាត់ឲ្យលោកទៅធ្វើការនៅក្រាំងតាចាន់។ ប៉ុន្តែក្នុងចម្លើយ D232/93 ចម្លើយលេខ៣ លោកបញ្ជាក់ថាមានមនុស្សប្រាំមួយនាក់ផ្សេងទៀត។ គឺលោកនៅក្នុងចំណោមក្រុមមនុស្សប្រាំមួយនាក់ ដែលគេបញ្ជូនទៅធ្វើការនៅក្រាំងតាចាន់រួមមានឈ្មោះ ស៊ាន់, ស៊ឹម...។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះពីមនុស្សចំនួនប្រាំមួយនាក់ដែលគេឲ្យទៅធ្វើការនៅក្នុងក្រាំងតាចាន់។ តើលោកស្ថិតនៅក្រុមតែមួយជាមួយមនុស្សប្រាំមួយនាក់នេះឬ?

[១០:៥៨:២៦]

**ឆ៖** បាទក្នុងចំណោមមនុស្សទាំងប្រាំមួយនាក់នេះ គឺគេបញ្ជូនទៅការពារនៅមន្ទីរក្រាំងតាចាន់។

**ស៖** សំណួរខ្ញុំ គឺមុនពេលគេចាត់តាំងលោកឲ្យធ្វើការនៅក្រាំងតាចាន់ តើមនុស្សទាំងអស់នេះស្ថិតនៅកង នៅក្រុមជាមួយលោកតែមួយ ឬក៏យ៉ាងណា មុនពេលទៅក្រាំងតាចាន់?

**ឆ៖** បាទ គឺស្ថិតនៅក្នុងកងតែមួយ។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតឲ្យសាក្សីពិនិត្យមើលឯកសារ ក.ស.ច.ស ចំនួនពីរគឺ D40.20 និង E319.1.33 គឺជាចម្លើយរបស់សាក្សីមួយផ្សេង។ ខ្ញុំមិនលើកឈ្មោះមកនិយាយទេ ប៉ុន្តែចង់ឲ្យ

សាក្សីរូបនេះមើលឯកសារទាំងពីរនេះ គឺនៅទំព័រខាងដើម និងជម្រាបជូនអង្គជំនុំជម្រះថាតើមនុស្សទាំងពីរនេះ ជាមនុស្សដែលស្ថិតនៅក្នុងក្រុមជាមួយនឹងគាត់ដែរឬក៏អត់ មុនពេលបញ្ជូនទៅក្រាំងតាចាន់? ហើយយើងខ្ញុំមិនចង់ឲ្យអានឈ្មោះហ្នឹងឮៗទេ គ្រាន់តែឲ្យគាត់ក្រឡេកមើល ថាតើគាត់ស្គាល់មនុស្សទាំងពីរនេះ ឬក៏អត់?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីសហព្រះរាជអាជ្ញារងអន្តរជាតិយកទៅជូនសាក្សីពិនិត្យ។

[១១:០០:៣៨]

**សួរដោយលោក ខេល លីសាក់**

**ស៖** សំណួររបស់ខ្ញុំ គឺនៅទំព័រដំបូងនៃឯកសារទាំងពីរហ្នឹង មានសរសេរឈ្មោះ និងព័ត៌មានអំពីបុគ្គលទាំងពីរនាក់នេះ។ បើលោកមើលទៅលើព័ត៌មាននៃបុគ្គលទាំងពីរនាក់នេះ គឺសំណួររបស់ខ្ញុំសួរថាតើមនុស្សទាំងពីរនាក់នេះ ជាមនុស្សដែលស្ថិតនៅក្នុងក្រុមជាមួយនឹងលោក ក្រុមតែមួយជាមួយនឹងលោកដែរឬក៏អត់ទេ មុនពេលបញ្ជូនទៅក្រាំងតាចាន់?

**លោក ស្រី ថន៖**

**ឆ៖** បាទ មនុស្សទាំងពីរនាក់នេះ ស៊ាន់ និង ស៊ីម នេះ គឺជាមនុស្សនៅក្នុងក្រុមតែមួយ។

**ស៖** បុគ្គលទី១ នៅក្នុងឯកសារ D40/20, ទំព័រភាសាខ្មែរ 00165329, ERN អង់គ្លេស 00433568, ERN ភាសាបារាំង 00524317។ បុគ្គលរូបនេះបញ្ជាក់ថាគាត់ត្រូវបានគេបញ្ជូនទៅក្រាំងតាចាន់ នៅក្នុងរដូវច្រូតកាត់នៅក្នុងឆ្នាំ១៩៧៦។ បុគ្គលទី២ ដែលលោកថាត្រូវបានចាត់តាំងឲ្យធ្វើការនៅក្រាំងតាចាន់ ពេលជាមួយនឹងលោកដែរនោះ គឺឯកសារ E319.1.33 នៅត្រង់ចម្លើយលេខ ១៥។ បុគ្គលរូបនេះឆ្លើយថាគេបានចាត់តាំងឲ្យគាត់ទៅធ្វើជាអ្នកយាមកាមនៅក្រាំងតាចាន់ នៅក្នុងខែតុលា ឬវិច្ឆិកា ឆ្នាំ១៩៧៦។ តើចំណុចនេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេ ថានៅចុងឆ្នាំ១៩៧៦ គឺមិនមែន៧៧ទេ គឺចុងឆ្នាំ១៩៧៦ ពេលដែលគេចាត់តាំងលោកឲ្យទៅធ្វើការនៅក្រាំងតាចាន់?

[១១:០២:៥៥]

**ឆ៖** បាទ មកដើម -- នៅចុងឆ្នាំ១៩៧៦ គេបានបញ្ជូនខ្ញុំ ប៉ុន្តែមិនមែនទៅនៅគុកក្រាំងតាចាន់ទេ គឺទៅនៅយាមខាងក្រៅចម្ងាយប្រហែលជាមួយគីឡូម៉ែត្រពីគុកក្រាំងតាចាន់។

**សៈ** សូមអរគុណចំពោះការឆ្លើយបំភ្លឺ។ ទាក់ទងទៅនឹងមុខងាររបស់លោកនៅឯ ក្រាំងតាចាន់ លោកបានឆ្លើយដូច -- ទាក់ទងទៅនឹងដំណើរការគុកក្រាំងតាចាន់ នៅក្នុងឯកសារ D125/129, ERN ជាភាសាខ្មែរ 00224789, ERN ជាភាសាអង់គ្លេស 00231674, ERN ជាភាសាបារាំង 00234575 ដែលលោកបានឆ្លើយដូចតទៅ៖ "ក្រាំងតាចាន់គឺជាមន្ទីរអប់រំកែប្រែ។ ខ្ញុំបានឮប្រជាជននិយាយតៗគ្នាថា មន្ទីរអប់រំ គឺជាកន្លែងសម្លាប់មនុស្ស។ អ្នកដែលត្រូវគេនាំចូលកន្លែងនេះ មិនអាចរស់បានទេ គឺស្លាប់ទាំងអស់"។ បញ្ចប់ការដកស្រង់។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថា លោកឮពីអ្នកណាដែលនិយាយអំពីមន្ទីរអប់រំកែប្រែនេះ?

[១១:០៥:៥៩]

**ឆៈ** បាទ ខ្ញុំឮប្រជារាស្ត្រខ្លាចថា មន្ទីរអប់រំស្រុកត្រាំកក់នេះគឺជាកន្លែងសម្លាប់មនុស្ស។

**សៈ** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ក្នុងពេញមួយអំឡុងពេលដែលលោកធ្វើការនៅក្រាំងតាចាន់ នៅមន្ទីរអប់រំក្រាំងតាចាន់ តើមានគ្រូបង្រៀននៅទីនោះទេ?

**ឆៈ** បាទ គ្មានទេ។

**សៈ** លោកបានរៀបរាប់នៅក្នុងចម្លើយជាមួយសហចៅក្រមស៊ើបអង្កេតថាពីដំបូងឡើយលោកធ្វើការជាអ្នកយាមកាមនៅខាងក្រៅក្រាំងតាចាន់ ហើយក្រោយមកគេក៏ឲ្យទៅធ្វើការនៅក្នុងបរិវេណខាងក្នុងឲ្យជួយវាយឯកសារ វាយអង្គុលីលេខ។ ទី១ ខ្ញុំចង់សួរលោកសំណួរមួយចំនួន អំពីថាតើអ្នកទោសហ្នឹងគេទៅដល់ក្រាំងតាចាន់ដោយរបៀបណា គឺពេលដំបូងដែលលោកធ្វើការនៅខាងក្រៅគុកក្រាំងតាចាន់ និងក្រោយមកធ្វើការនៅខាងក្នុងគុកក្រាំងតាចាន់។ នៅក្នុងចម្លើយរបស់លោក D125/129, ខ្មែរ ERN 00224789, ERN ភាសាអង់គ្លេស 00231674 ហើយ ERN ភាសាបារាំង 00234575។ លោកបានរៀបរាប់ថាតើប្រជាជនត្រូវគេចាប់ខ្លួនដោយរបៀបណានោះ គឺខ្ញុំសូមដកស្រង់ "គឺគេដើរចូលក្នុងគុកដោយគេចងស្លាបសេកមកខាងក្រោយ"។ បញ្ចប់ការដកស្រង់។ សូមលោកប្រាប់ផងថា អ្នកណាជាអ្នកនាំមនុស្សដែលគេចាប់ខ្លួន ដែលគេចងស្លាបសេកយកមកក្រាំងតាចាន់? អ្នកណាជាអ្នកចាប់?

[១១:០៧:៣០]

**ឆៈ** បាទ ពេលដែលគេបញ្ជូនមនុស្សមក ខ្ញុំមិនដឹងជាខាងណាជាអ្នកចាប់ទេ ប៉ុន្តែជូនមកពីឃុំភូមិ គេបញ្ជូនមក។

**សៈ** តើលោកកំពុងតែឆ្លើយថា គឺឈ្លបឃុំជាចាប់អ្នកទោសហ្នឹងមក ឬក៏យ៉ាងណា? ខ្ញុំសួរថា

អ្នកណាអ្នក -- ជាអ្នកនាំអ្នកទោសមកបរិវេណខាងក្រៅគុក ក្រាំងតាចាន់?

**ឆ៖** បាទ មិនមែនឈ្លបឃុំអ្នកចាប់ទេ អ្នកទោសដែលគេបញ្ជូនមកហ្នឹងគេចងហើយស្រេច គេបញ្ជូនមក ប៉ុន្តែមិនដឹងពីខាងណាអ្នកចាប់ទេ ខ្ញុំមិនដឹង។

**សៈ** ខ្ញុំសួរ -- ខ្ញុំមិនសួរថាអ្នកណាអ្នកចាប់ តែឥឡូវសួរគឺប្រជា -- ខ្ញុំៗមិនសួរអ្នកណាអ្នកចាប់ទេ ខ្ញុំសួរអ្នកណាជាអ្នកនាំខ្លួនអ្នកទោសមកគុកក្រាំងតាចាន់ មកខាងក្រៅបរិវេណគុកក្រាំងតាចាន់?

**ឆ៖** បាទ អ្នកនាំមកគឺឈ្លបឃុំ។

[១១:០៩:១៧]

**សៈ** លោកសាក្សីសៀវភៅមួយក្បាលដែលសរសេរដោយមនុស្សម្នាក់ឈ្មោះ អ៊ា ម៉េងទ្រី ដែលជាឯកសារនៅក្នុងសំណុំរឿងនេះ។ ខ្ញុំយោងទៅលើឯកសារ E3/2120 សៀវភៅមួយក្បាលនេះយោងទៅលើកិច្ចសម្ភាសន៍ដែល អ៊ា ម៉េងទ្រី ជាអ្នកធ្វើ។ ជាសម្ភាសនៅក្នុងឆ្នាំ២០០១ ហើយបុគ្គលដែលគាត់សម្ភាសហ្នឹង ខ្ញុំសូមដកស្រង់ឈ្មោះ សុខ ចាន់ថា ហៅ ឌុច អតីតកម្មាភិបាលមន្ទីរអប់រំគុកក្រាំងតាចាន់ ជាអ្នកវាយអង្គលីលេខ។ សំណួររបស់ខ្ញុំសួរថា លោកចាំថា លោកធ្លាប់បាន អ៊ា ម៉េងទ្រី សម្ភាសអំពីគុកក្រាំងតាចាន់នៅក្នុងឆ្នាំ២០០១ទេ?

**ឆ៖** បាទ អត់ចាំទេ។

**សៈ** លោកដែលប្រើឈ្មោះលោកហៅក្រៅថា ឈ្មោះ សុខ ចាន់ថា ទេ?

**ឆ៖** បាទ អត់មានទេ។

**សៈ** ខ្ញុំសុំអានសម្រង់ខ្លីមួយឲ្យលោកស្តាប់ដើម្បីជួយរំឭកដល់ការចងចាំរបស់លោក។

ក្នុងសៀវភៅ E3/2120 នេះ។ សម្រង់គឺ ERN អង់គ្លេស 00416390, សម្រង់នេះ មិនទាន់បានបកប្រែពេញលេញនៅឡើយទេ។ ដូច្នេះ ដើម្បីជាប្រតិចារឹក គឺខ្ញុំបានស្នើសុំឲ្យធ្វើការបកប្រែនៅទំព័រនេះ គឺចម្លើយមានដូចតទៅគឺជាបុគ្គលម្នាក់ដែលបាននិយាយថា៖ “ខ្លួនគឺជាអ្នកវាយអង្គលីលេខនៅក្រាំងតាចាន់ ហៅ ឌុច ហើយនិងអ្នកយាមម្នាក់ឈ្មោះ សេង”។ កម្មាភិបាលទាំងនេះគឺបានរាយការណ៍ថា អ្នកទោស-- សូមដកស្រង់ “បានវាយជួងដែលគេព្យួរនៅដើមស្វាយនៅខាងលិច នៅពេលឮជួង កម្មាភិបាលចេញមកទទួលយកអ្នកទោសនៅខាងក្រៅ ហើយនាំចូលទៅខាងក្នុងបន្ទប់”។ បញ្ចប់ការដកស្រង់។ តើមានជួងនៅក្រៅបរិវេណគុកក្រាំងតាចាន់ទេ? គឺជួងដែលសេនាជននាំអ្នកទោសទៅ ហើយអ្នកសេនាជនហ្នឹងគេក៏បានវាយជួងហ្នឹង។ តើមានជួងនៅខាងក្រៅគុកហ្នឹងទេ?

**ឆ៖** គ្មានទេ។

[១១:១៣:០៥]

**ស៖** ឥឡូវខ្ញុំសុំសួរសំណួរមួយចំនួនអំពីចំនួនអ្នកទោស ដែលគេឃុំនៅក្រាំងតាចាន់។ នៅក្នុងចម្លើយរបស់លោក D232/93 នៅត្រង់ចម្លើយ១៩ និងចម្លើយ២០ លោកបានឆ្លើយដូចតទៅ "ស៖ តើពេលបញ្ជូននោះ អ្នកទោសមានចងមុខដែរឬទេ? ឆ៖ មិនមានចងមុខទេ គឺគេចងតែដៃប៉ុណ្ណោះ។ ពេលគេចងដៃបណ្ដើរម្ដងៗ មានគ្នាប្រហែល ប្រាំទៅប្រាំមួយនាក់បន្តគ្នា។ ស៖ តើអ្នកទោសច្រើនបំផុតមានប៉ុន្មាននាក់? ឆ៖ ថ្ងៃខ្លះមានចំនួនប្រហែល២០នាក់ក៏មាន ថ្ងៃខ្លះមានបីបួននាក់ក៏មាន"។ បញ្ចប់ការដកស្រង់។

ចំណុចទី១ ដែលខ្ញុំចង់ឲ្យលោកឆ្លើយបញ្ជាក់នៅពេលដែលលោកនិយាយថាច្រើនបំផុត ថ្ងៃខ្លះមានប្រហែល២០នាក់។ តើលោកនិយាយសំដៅទៅលើអ្នកទោសភាគច្រើនបំផុត ដែលមកដល់ក្នុងថ្ងៃណាមួយ ឬក៏លោកនិយាយថាគុកហ្នឹងដាក់បានតែ២០នាក់។ តើលោកចង់និយាយថាម៉េចកន្លែងហ្នឹង? ពេលដែលលោកនិយាយថា "ថ្ងៃខ្លះមានអ្នកទោសប្រហែល២០នាក់ហ្នឹង"?

**ឆ៖** បាទ ចម្លើយដែលនិយាយថា មានអ្នកទោស បួនដប់ម្ភៃនាក់ហ្នឹង គឺដោយថ្ងៃ ជួនកាលថ្ងៃណាដែលអ្នកទោសគេបញ្ជូនមក បួនដប់ ឬម្ភៃនាក់ហ្នឹង ក្នុងរយៈពេលមួយថ្ងៃ ហើយវាមិនកំណត់រៀងរាល់ថ្ងៃទេ។

[១១:១៥:០០]

**ស៖** ខ្ញុំសូមបញ្ជាក់ គឺលោកនិយាយអំពីអ្នកទោសដែលគេនាំខ្លួនមកដល់។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** យើងបានស្ដាប់ឮសក្ខីកម្មពីដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ឈ្មោះ សយ សែន គាត់បានរៀបរាប់ថាពីដំបូងឡើយមានអគារពីរសម្រាប់ឃុំឃាំងអ្នកទោស។ ក៏ប៉ុន្តែនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យប្រហែលជាពេលខ្លះ ក្រោយថ្ងៃ១៧ មេសា ៧៥ គឺគេមានសង់អគារពីរបន្ថែមទៀត។ សំណួរទី១ របស់ខ្ញុំ តើលោកនៅចាំបានទេថា ចំនួនអគារនៅឯក្រាំងតាចាន់ ដែលគេអាចប្រើប្រាស់សម្រាប់ឃុំអ្នកទោស លោកអាចប៉ាន់ប្រមាណមើលថា អគារនីមួយៗគេអាចដាក់អ្នកទោសបានប៉ុន្មាននាក់?

**ឆ៖** បាទ អគារអ្នកទោសមានពីរនៅក្នុងគុកក្រាំងតាចាន់។ អគារមួយៗដាក់អ្នកទោសបានប្រហែលជា ៥០ ទៅ ៦០ នាក់ ក្នុងអគារមួយ។

**ស៖** បាទ ខ្ញុំនឹងត្រឡប់មកចំណុចនេះនៅពេលបន្តិចទៀត។ នេះជាសក្ខីកម្មរបស់ សយ សែន នៅត្រង់ E1/257 គឺៗប្រតិចារឹកថ្ងៃទី០៥ កុម្ភៈ ២០១៥ នៅម៉ោង ១០:៥០:៥៣វិនាទី គាត់ថា៖ "ដោយសារអ្នកទោសមានចំនួនកើនច្រើនឡើង អ៊ីចឹងគេក៏សាងសង់អគារពីរទៀត នៅផ្នែកខាងកើតនៃបរិវេណនោះ"។ តើចំណុចត្រង់នេះវាជួយរំឭកដល់ការចងចាំរបស់លោកថាគេមានសង់អគារពីរបន្ថែមទៀតទេ គឺវាមិននៅក្នុងបរិវេណទេ គ្រាន់តែសង់នៅខាងក្រៅនៅបរិវេណហ្នឹងបន្តិច?

**ឆ៖** បាទ បើពីមុនមកហ្នឹងខ្ញុំមិនបានចាំទេ ហើយខ្ញុំក៏អត់បានដឹងដែរ ប៉ុន្តែពេលដែលខ្ញុំទៅនៅហ្នឹង ឃើញតែអគារពីរទេ មានអគារខាងលិចមួយ ខាងកើតមួយ។

[១១:១៨:៣៥]

**លោក ឌេល លីសាក់៖**

ឯកសារមួយដែលជាភស្តុតាងនៅក្នុងសម្រាប់តុលាការនេះគឺគេនិយាយអំពីខែវិច្ឆកា ឆ្នាំ១៩៧៧ របាយការណ៍ពីគុកហ្នឹង។ លោកប្រធានខ្ញុំសូមការអនុញ្ញាតផ្តល់ឯកសារនេះជូនសាក្សីមើល ហើយនិងសុំដាក់បញ្ចាំងនៅលើអេក្រង់ផង គឺឯកសារ E3/2109, ERN ភាសាខ្មែរ 00068014, អង់គ្លេស 00276555, បារាំង 00290272។ លោកប្រធានខ្ញុំអនុញ្ញាតដើម្បីបង្ហាញឯកសារនេះបញ្ចាំងនៅលើអេក្រង់ផង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីខ្ញុំសូមបង្ហាញកថាខណ្ឌ គឺកថាខណ្ឌ១នៃឯកសារនោះ។ ខ្ញុំសូមបង្ហាញផ្នែកនេះនៅលើអេក្រង់ដែលជារបាយការណ៍របាយការណ៍អំពីចំនួនអ្នកទោសនៅខែ១១ ឆ្នាំ១៩៧៧ ដូចតទៅថា អ្នកទោសចំនួន ៧៥នាក់ថ្មីបានចូលមកក្នុងគុក ហើយ៩២ បានបោសសម្អាត ៦នាក់បានស្លាប់ ហើយម្នាក់ដែលជាអនុសេនីយ៍ឯកគឺដកទៅតំបន់នៅដំណាច់ខែ។ សំណួរ -- សព្វថ្ងៃនៅសល់ទាំងអស់ ៨៥ នាក់។ សំណួររបស់ខ្ញុំតើលោក ធ្លាប់ដែលបានរាយការណ៍ពីចំនួនអ្នកទោសបែបនេះ រាយការណ៍ពីចំនួនអ្នកទោសប្រចាំខែអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អត់ដែលបានទេ។

**ស៖** លោកចាំអក្សរដែលសរសេរដោយដៃនៅក្នុងរបាយការណ៍នេះទេ?

**ឆៈ** បាទ ចាំ។ អក្សរនេះគឺអក្សរ ឌុច។

**សៈ** ពេលលោកនិយាយថាជាអក្សរ ឌុច។ ឌុច ហ្នឹងជាអ្នកណា?

**ឆៈ** ឌុច គឺជាអនុប្រធានរបស់លោក ឡេង អាន់។

**សៈ** ដើម្បីជាប្រតិចារឹក គឺមានកម្មាភិបាលពីរនាក់ធ្វើការនៅក្រាំងតាចាន់ មានឈ្មោះហៅក្រៅ ឌុច ដូចគ្នា។ គឺមានលោកខ្លួនឯង និងមនុស្សម្នាក់ទៀត ដែលលោកទើបនិយាយថា ជាអនុប្រធានគុក ឈ្មោះ ឌុច ដែរ តើត្រឹមត្រូវទេ?

**ឆៈ** បាទ ត្រឹមត្រូវ។

[១១:២២:៤៦]

**សៈ** របាយការណ៍មួយនេះ និយាយថា មនុស្សម្នាក់ អ្នកទោសម្នាក់ពាក់ស័ក្តិ៤កន្លះ ត្រូវបាន ដកទៅតំបន់ ត្រូវបានអង្គការដកទៅតំបន់។ តើលោកចង់និយាយថាម៉េច ពាក្យថា "ដកទៅតំបន់ហ្នឹង"?

**ឆៈ** បាទ អត់យល់។

**សៈ** តើមានមន្ទីរសន្តិសុខតំបន់នៅក្នុងស្រុកត្រាំកក់ដែរឬទេ? តើមានមន្ទីរសន្តិសុខថ្នាក់តំបន់ មានទីតាំងនៅក្នុងស្រុកត្រាំកក់ទេ?

**ឆៈ** បាទ ខ្ញុំអត់ដឹង។

**សៈ** ខ្ញុំសូមសួរមួយសំណួរទៀត តើនៅពេលណាមួយលោកដឹងថា គេបានបញ្ជូនអ្នកទោស ចេញពីគុកក្រាំងតាចាន់ ទៅគុកផ្សេងទៀតទេ?

**ឆៈ** បាទ មាន ប៉ុន្តែគ្មានកន្លែងគុកទៀតទេ។ មានឃើញបញ្ជូនចេញ ប៉ុន្តែមិនដឹងគេយកទៅ ណាទេ។

**សៈ** តើគេបញ្ជូនអ្នកទោសចេញទៅទីកន្លែងផ្សេងៗញឹកញាប់ប៉ុនណាដែរ?

**ឆៈ** បាទ មិនញឹកមិនញាប់ទេ។ ពេលដែលគេបញ្ជូន ឃើញបញ្ជូនគឺនៅចុងឆ្នាំ១៩៧៨ ដើម ឆ្នាំ១៩៧៩ ទៅហើយ។

[១១:២៥:00]

**សៈ** តើលោកមានព័ត៌មានថា តើអ្នកទោសទាំងនេះ គេបញ្ជូនចេញទៅឯណាចុងឆ្នាំ១៩៧៨ ឬ ក៏ដើមឆ្នាំ១៩៧៩ហ្នឹង?

**ឆៈ** បាទ ខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំបានយោងទៅលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ដែលបាន -- ដែលមានឈ្មោះថា សយ សែន នៅក្នុងចម្លើយរបស់លោកជាមួយសហចៅក្រមស៊ើបអង្កេត គឺD125/129, ERNជាភាសាខ្មែរ 00224790 ដល់ 91, ERN ជាភាសាអង់គ្លេស 00231675 ហើយERN ជាភាសាបារាំង 00234576។ នៅក្នុងចម្លើយរបស់លោកនេះ លោកបានកំណត់ឈ្មោះ ស្គាល់ឈ្មោះ សយ សែន ថាជាអ្នកទោសម្នាក់ដែលរស់រានមានជីវិតពីគុកក្រាំងតាចាន់។ តើលោកអាចបញ្ជាក់បានថា សយ សែន ពិតជាអ្នកទោសនៅក្រាំងតាចាន់មែនទេ នៅក្នុងពេញអំឡុងមួយពេលដែលលោកធ្វើការនៅក្រាំងតាចាន់?

**ឆ៖** បាទ ឈ្មោះ សយ សែន ពិតជាអ្នកទោសនៅក្នុងគុកក្រាំងតាចាន់មែន ប៉ុន្តែមិនដឹងជាជាប់ពីឆ្នាំណាមកទេ ពេលដែលខ្ញុំចូលទៅ គឺឃើញលោក សយ សែន នៅក្នុងហ្នឹងហើយស្រេច។

**ស៖** ដូច្នេះលោកបញ្ជាក់ថា ពេលដែលលោកទៅដល់ទីនោះគឺ សយ សែន នៅទីនោះរួចស្រេច។ តើគាត់ជាប់គុកនៅក្រាំងតាចាន់ រហូតពេញមួយអំឡុងពេលដែលលោកធ្វើការនៅទីនោះឬ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនច្បាស់ ខ្ញុំឮសួរសហព្រះរាជអាជ្ញា -- ខ្ញុំឮអ្នកទោសឆ្លើយទៅជាអតីតអ្នកទោស។ សាក្សីឆ្លើយថា "អតីតអ្នកទោស"។

**លោក ឌេល លីសាក់៖**

ហើយក្រោយមក គាត់និយាយថា "នៅពេលដែលខ្ញុំទៅដល់ក្រាំងតាចាន់ គាត់នៅទីនេះរួចទៅហើយ"។

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

[១១:២៨:១២]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសូមបញ្ជាក់លោកប្រធាន។ នៅពេលលោកនិយាយថា "សយ សែន នៅក្រាំងតាចាន់

រួចទៅហើយ នៅពេលដែលយកទៅដល់នៅចុងឆ្នាំ១៩៧៦”។ តើគាត់ជាអ្នកទោសអត់ពេលហ្នឹង?

**លោក ស្រី ផន៖**

**ឆ៖** បាទ ពេលដែលខ្ញុំទៅដល់នៅដើមឆ្នាំ១៩៧៧ ខ្ញុំឃើញឈ្មោះ សយ សែន នៅក្នុងគុកក្រាំងតាចាន់រួចស្រេចទៅហើយ ប៉ុន្តែគេឲ្យនៅខាងក្រៅ គេមិនឲ្យនៅក្នុងគុកទេ ប៉ុន្តែគេឲ្យនៅក្រៅដាំបាយដាំអី។

**ស៖** នៅពេលថាគេឲ្យនៅក្រៅដាំបាយ គឺដាំបាយនៅពេលថ្ងៃ ឬក៏យ៉ាងម៉េច? ចុះពេលយប់គេតើគាត់នៅឯណា?

**ឆ៖** ពេលយប់ គេបញ្ចូលក្នុងគុកដដែល។

**ស៖** តើលោក សយ សែន ហ្នឹងនៅជាប់ក្រាំងតាចាន់ ពេញរយៈពេលដែលលោកធ្វើការនៅទីនោះ ឬក៏យ៉ាងណា?

**ឆ៖** បាទ ពេលដែលខ្ញុំនៅក្រាំងតាចាន់ ហ្នឹងប្រហែលជារយៈពេលជិតមួយឆ្នាំតែប៉ុណ្ណោះហើយ សយ សែន គឺនៅហ្នឹងរហូត។

[១១:២៩:៥៥]

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅប្រធានបទផ្សេង។ ប្រធានបទស្ដីអំពីការសួរចម្លើយអ្នកទោសនៅគុកក្រាំងតាចាន់។ នៅក្នុងចម្លើយជាមួយនឹងសហចៅក្រមស៊ើបអង្កេត គឺឯកសារ D125/129, ERN ជាភាសាខ្មែរ 00224790, អង់គ្លេស 00231675 និង ERN ភាសាបារាំង 00234576។ លោកឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ “ខ្ញុំធ្លាប់ឃើញគេយកអ្នកទោសទៅវាយដំសួរចម្លើយរៀងរាល់ថ្ងៃ នៅក្នុងបន្ទប់សួរចម្លើយប្រហែលជា ៥០ម៉ែត្រពីរោងខ្ញុំធ្វើការ។ ខ្ញុំឮអ្នកទោសស្រែកចេញពីបន្ទប់សួរចម្លើយ”។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំសូមសួរថា តើបន្ទប់សួរចម្លើយមានទីតាំងនៅក្នុងបរិវេណគុកក្រាំងតាចាន់ ឬក៏អត់ទេ?

**ឆ៖** បាទ កន្លែងសួរចម្លើយគឺនៅក្នុងទីតាំងគុកក្រាំងតាចាន់ហ្នឹង។

**លោក ខេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតបង្ហាញឯកសារជូនទៅសាក្សី គឺឯកសារ D125/220.37 គឺជាផែនទីរបស់សហចៅក្រមស៊ើបអង្កេត។ បើលោកប្រធានអនុញ្ញាត ខ្ញុំក៏សូមការអនុញ្ញាតបង្ហាញលើអេក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១១:៣២:៥៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី បើលោកមើលទៅផ្សាក្រោមនេះ គំនូសបង្ហាញនេះ តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេ។ ខ្ញុំសូមបង្ហាញត្រង់ផ្នែកខាងក្រោមនៃបរិវេណផែនទីបរិវេណ គឺមានអគារមួយដែលគេនៅភាគខាងត្បូង គឺមាននិយាយអំពីកន្លែងសួរចម្លើយ។ តើផែនទីនេះបង្ហាញពីបន្ទប់សួរចម្លើយហ្នឹងត្រឹមត្រូវដែរឬទេ នៅគុកក្រាំងតាចាន់ហ្នឹង?

**លោក ស្រី ថន៖**

**ឆ៖** បាទ ពេលដែលខ្ញុំចូលទៅ គឺអត់មានទីតាំងនេះអ៊ីចឹងទេ។

**ស៖** តើលោកអាចជម្រាបបានទេ តើវា -- ទីតាំងដែលគេបង្ហាញហ្នឹង គឺថាវាដូចទៅនឹងដូចគេបង្ហាញនៅលើផែនទីនេះទេ ទីតាំងកន្លែងនុ៎ង?

**ឆ៖** បាទ ខ្ញុំមិនចាំទេ ប៉ុន្តែដូចជាគ្មានទីតាំងរបៀបនេះទេ។

**ស៖** ខ្ញុំសូមសួរលោកថាតើលោកចាំថាធ្លាប់មានផ្ទះបាយ ឬក៏កន្លែងហូបបាយដែលមានទីតាំងនៅជិតបន្ទប់សួរចម្លើយទេ?

**ឆ៖** បាទ អត់មានទេ។

[១១:៣៥:០០]

**ស៖** តើមានកន្លែងរោងបាយដាក់លាក់ទេសម្រាប់អ្នកយាម គឺរោងបាយ ខុសពីរោងបាយអ្នកទោស?

**ឆ៖** អ្នកទោសគ្មានរោងបាយទេ។

**ស៖** បាទ ខ្ញុំចោទសំណួរបើកចំហមួយ។ តើអ្នកយាមហូបចុកហ្នឹងនៅកន្លែងណា នៅក្នុងបរិវេណគុកហ្នឹង? ហើយអ្នកទោសនោះគាត់ហូបចុកនៅកន្លែងណាដែរ?

**ឆ៖** បាទ ខ្ញុំបាទអ្នកយាមគ្នាប្រាំមួយនាក់ គឺហូបបាយដោយខ្លួន អ្នកទោសគេហូបបាយដោយខ្លួន អត់ហូបបាយចូលគ្នាទេ។ ហើយទីតាំងហូបបាយនោះ មិនពិតប្រាកដទេ មួយថ្ងៃហូបត្រង់នេះ មួយ

ថ្ងៃហូបត្រង់នោះ។

**ស៖** ខ្ញុំសួរទៅលើរយៈពេលដែលលោកធ្វើការនៅក្នុងបរិវេណគុកទ្ទុំង។ លោកបានឆ្លើយថា នៅពេលនោះ លោកជាអ្នកជួយវាយអង្គុលីលេខ។ នៅក្នុងរយៈពេលហ្នឹង តើលោកហូបចុកនៅកន្លែងណាដែរ?

[១១:៣៦:៤៣]

**ឆ៖** បាទ នៅពេលនោះ ខ្ញុំបាទហូបបាយនៅជាមួយនឹងក្រុមរបស់ខ្ញុំដដែល។

**ស៖** តើអ្នកទោសហូបចុកនៅកន្លែងណាដែរ?

**ឆ៖** អ្នកទោសហូបនៅក្នុងគុកដដែល។

**ស៖** ខ្ញុំសូមបញ្ជាក់ក្រែងលោមានបញ្ហាបកប្រែ។ អម្បាញ់មិញខ្ញុំលែងនិយាយអំពីរោងបាយហើយៗ ខ្ញុំមិននិយាយពី -- ខ្ញុំសួរថាតើមានរោងបាយដែរឬអត់នៅក្នុងបរិវេណគុកក្រាំងតាចាន់នោះ? បើសិនជាមាននោះតើនៅកន្លែងណាដែរ?

**ឆ៖** កន្លែងនោះមានរោងបាយ ប៉ុន្តែរោងបាយនោះគេលែងដាំទៅហើយ គឺចាស់។ ពេលដែលខ្ញុំចូលទៅដល់នោះ រោងបាយហ្នឹងគេលែងដាំទៅហើយ។

**ស៖** នៅក្នុងកន្លែងក្នុងបរិវេណហ្នឹង តើគេដែលធ្វើម្ហូបអាហារនៅកន្លែងណា?

**ឆ៖** ខ្ញុំដូចពិបាកនិយាយត្រង់ថា ធ្វើនៅកន្លែងណា។ គ្មានកន្លែងពិតប្រាកដត្រូវធ្វើ។ ចង្ក្រានដាក់លើកដាំ។ គ្មានកាស៊ីនបាយពិតប្រាកដ គ្មានឆ្នាំង គ្មានចង្ក្រានអីពិតប្រាកដទេ។ ក្រុមគេ -- ក្រុមខ្ញុំប្រាំមួយនាក់ កងការពារគឺហូបដោយខ្លួន។

[១១:៣៩:២២]

**ស៖** មុននឹងបញ្ចប់សំណួរទាក់ទងទៅនឹងរោងបាយនេះ -- តើលោកបាននិយាយថា លោកបានហូបចុកជាមួយក្រុមរបស់លោកដែលមានគ្នាប្រាំមួយនាក់ហ្នឹង។ នៅពេលដែលលោកធ្វើការនៅក្នុងបរិវេណ តើមានអគារណាមួយ ឬក៏កន្លែងណាមួយជាក់លាក់ដែលលោកហើយនិងអ្នកយាមផ្សេងទៀតហូបចុកដែរឬទេ?

**ឆ៖** ក្រុមខ្ញុំប្រាំមួយនាក់ គឺមានអគារ -- មានរោងពីរ គឺនៅមាត់ច្រកខាងលិចមួយនិងមាត់ច្រកខាងកើតមួយ។ ហើយមួយក្រុមហ្នឹងមានគ្នាបីនាក់ គឺយាមម្ខាងមាត់ទ្វារខាងកើត គឺម្ខាងមាត់ទ្វារខាងលិច។ ពេលហូបបាយ គឺជួនកាលទៅហូបខាងលិច ជួនកាលមកហូបរោងខាងកើត។

**ស៖** បាទ ឥឡូវខ្ញុំសុំចូលទៅប្រធានបទថ្មីមួយទៀត។

**ប្រធានអង្គជំនុំ៖**

បាទៗ ដល់ពេលសម្រាកហើយ ហើយមុននឹងសម្រាកហ្នឹង អង្គជំនុំជម្រះសូមជម្រាបជូនដល់ទៅសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺ មានពេលមួយរសៀលនេះទៀតនៅក្នុងការសួរដេញដោលចំពោះការសួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបផងដែរថា អង្គជំនុំជម្រះបានសម្រេចផ្តល់វិធានការការពារដល់សាក្សី 2-TCW-944 ដែលរួមមានការមិនបញ្ចេញអាសយដ្ឋាន និងមិនបញ្ចេញរូបភាពសាក្សីរូបនេះទៅឲ្យសាធារណជន។ ហើយនៅក្នុងសវនាការលើស្តាប់សក្ខីកម្មសាក្សីរូបនេះ ប្រព័ន្ធផ្សព្វផ្សាយត្រូវបានបង្គាប់មិនឲ្យផ្សព្វផ្សាយរូបថត ឬរូបភាពរបស់សាក្សីនេះ បើទោះបីរូបភាពពីមុនក៏ដោយ។ នេះសូមឲ្យជ្រាប។

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោង --

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤២:៣០]

បាទ ឥឡូវនេះសវនាការនៅថ្ងៃនេះ គឺយើងអង្គជំនុំជម្រះសម្រេចផ្អាកសវនាការត្រឹមនេះ។ សវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះ លើកបន្តធ្វើនៅថ្ងៃ២៣ ខែកុម្ភៈ ឆ្នាំ២០១៥។ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។

ហើយសាក្សី ការស្តាប់សក្ខីកម្មរបស់លោកមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ទៀត ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ ហើយមេធាវីប្រឹក្សាសាក្សីដូចគ្នា។ សូមអញ្ជើញចូលរួមតាមកាលវេលាដែលបានកំណត់នេះ។

សូមអញ្ជើញ លោកមេធាវី លោក ឌុច ផារី!

[១១:៤៣:៣០]

**លោក ឌុច ផារី៖**

សូមគោរពឯកឧត្តមប្រធាន។ ដូចខ្ញុំបានជម្រាបទៅខាងអង្គភាពគាំពារ និងសាក្សីរួចហើយថា នៅថ្ងៃច័ន្ទទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ នៅពេលព្រឹក ខ្ញុំមិនអាចមានវត្តមានបានទេ។ ខ្ញុំអាចមានវត្តមានបាននៅពេលរសៀល បាទ។ សូមអរគុណឯកឧត្តមប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណនូវការជូនព័ត៌មាននេះ។ ហើយអង្គជំនុំជម្រះមិនបានដឹងព័ត៌មាននេះពីមុនទេ ហើយអង្គជំនុំជម្រះនឹងលែលកអាចនឹងមានអ្នកជំនួសមេធាវីប្រឹក្សា ជំនួសនៅក្នុងអំឡុងពេលដែលលោក ផារី អវត្តមាននៅក្នុងករណីនេះ។

បាទ ដូច្នេះអង្គជំនុំជម្រះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃទី២៣ កុម្ភៈ ឆ្នាំ២០១៥ វេលាម៉ោង ចាប់ពីម៉ោងប្រាំបួនព្រឹក។ ដូច្នេះលោកអាចវិលត្រឡប់ទៅកាន់ទីលំនៅ ឬក៏កន្លែងណាដែលលោកស្នាក់នៅវិញបានហើយ ហើយសូមអញ្ជើញចូលរួមតាមការកំណត់នេះ។ ហើយភាគីដូចគ្នា គឺអង្គជំនុំជម្រះសូមអញ្ជើញភាគីចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ ដែលនឹងធ្វើបន្តនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ចាប់ផ្តើមម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និង អ្នកជំនាញក្នុងការជូនសាក្សីរូបនេះ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ។ ហើយនិងឲ្យអញ្ជើញគាត់វិលត្រលប់មកចូលរួមសវនាការបន្តផ្តល់សក្ខីកម្មថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួន គាត់ត្រលប់មកចូលរួមសវនាការនេះវិញនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ឲ្យបានមុនៗម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១១:៤៥ នាទី)*